សុន្ទរកថារបស់ **ឯកឧត្តម ហ្សីណូអ៊ុជិ ហ៊ីដេហ៊ីសា**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ

27 ធ្នូ 2018

- សូមគោរពលោក TEZUKA Koji អនុប្រធានការិយាល័យអាស៊ីអាគ្នេយ៍នៃអង្គការក្រៅរដ្ឋាភិបាល Heart of Gold
- សូមគោរពលោកស្រី MINAMI Yumiko នាយិកាអង្គការ FIDR
- សូមគោរពភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។

ខ្ញុំសូមជំរាបជូនអំពីគម្រោងដែលបានចុះហត្ថលេខាដូចតទៅ:

គម្រោងទីមួយសម្រាប់អង្គការ Heart of Gold រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាប្រមាណ 396,000 ដុល្លារអាមេរិក សម្រាប់ការកែទម្រង់កម្មវិធីសិក្សា បណ្តុះបណ្តាលធនធានមនុស្ស ថែរក្សាអគារព្រមទាំងដើម្បីឲ្យវិទ្យាស្ថានជាតិអប់រំកាយនិងកីឡាក្លាយជាវិទ្យាស្ថានគរុកោសល្យ4ឆ្នាំ ក្នុងមុខវិជ្ជាអប់រំកាយ។ ខ្ញុំសង្ឃឹមថាតាមរយៈគម្រោងនេះ បរិយាកាសនៃការបណ្តុះបណ្តាលគ្រូឯកទេសអប់រំកាយនៅកម្ពុជានឹងមានការរីកចំរើន ហើយវិស័យអប់រំកាយនៅកម្ពុជានឹងកាន់តែមានការអភិវឌ្ឍន៍ថែមទៀត។

គម្រោងទីពីរសម្រាប់អង្គការ FIDR រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាប្រមាណ 297,000 ដុល្លារអាមេរិក សម្រាប់ការលើកកម្ពស់ផលិតភាពនៃការដាំដុះស្រូវ ការធ្វើពិពិធកម្មនៃកសិកម្ម ការកែលម្អចំណីអាហារ ការបង្កើតបណ្តាញនៃប្រជាជនដែលរស់នៅក្នុងតំបន់ និងការពង្រឹងសហប្រតិបត្តិការក្នុងវិស័យកសិកម្មនៅក្នុងស្រុកបីនៃខេត្តកំពង់ឆ្នាំង។ ខ្ញុំរំពឹងថាតាមរយៈគម្រោងនេះ ប្រជាជនដែលរស់នៅក្នុងតំបន់ អាចកែលម្អជីវភាពរស់នៅរបស់ពួកគេ ទទួលទានអាហារគ្រប់គ្រាន់និងមានជីវជាតិ និង ថែរក្សាសុខភាពបានល្អ។

ជាទីបញ្ចប់ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមមានសុខភាពល្អ សុភមង្គល និង សូមឲ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណ។

**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No.61PR-18/EoJ 27 December 2018

## Japan Provides US$692,522 for Developing 4-year University of Physical Education Course and Food and Nutrition Security Project

The Government of Japan has agreed to provide US$692,522 in total for two recipient organisations under the framework, *the Grant Assistance for Japanese NGO Projects*. The Grant Contracts have been signed today between H.E. Mr. HORINOUCHI Hidehisa, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of the two recipients respectively, to carry out the following projects:

1. ‘Project on Developing 4-year University of Physical Education Course at National Institute of Physical Education Sport ’ (US$396,033)
Recipient: Heart of Gold
Heart of Gold will support National Institute of Physical Education and Sport to develop 4-year university of Physical Education course by improving curriculum, training teachers and installing facilities for physical education.
Through this project, approximately 65 staff and 200 teacher trainees in the institute will be able to gain better environment for physical education. And also around 800,000 students in this country are expected to receive more effective physical education.

2. ‘Food and Nutrition Security Project in Kampong Chhnang Province (Year 2)’ (US$296,489)
Recipient: Foundation for International Development/Relief (FIDR)
In this project, the organization will support farmers and related partners to improve the productivity of rice farming, to diversify farms, to improve children's nutrition status, to enhance farmers’ networks and ability of agricultural cooperatives in Rolea Pheir District, Tuek Phos District and Boribo District in Kampong Chhnang Province. Around 25,000 people in target area are expected to take sufficient nutritious food and maintain good health through these activities.

*The Grant Assistance for Japanese NGO Projects* started in Cambodia in 2002 to support

activities by Japanese NGOs to help Cambodia's reconstruction and development efforts at the grassroots level. Since 2002, the Government of Japan has provided over US$27 million for 113 projects, mainly in the field of primary education, health, agriculture and mine clearance. The two projects are the fifth and sixth ones funded by this grant scheme in Cambodia in the Japanese fiscal year 2018 (April 2018 - March 2019).

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161, fax: 023-214-330*
*Email: eco.jpn@pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្ដីប្រកាសព័ត៌មាន

លេខ. 61 PR-18/EoJ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨

## ជប៉ុនផ្ដល់ ៦៩២,៥២២ដុល្លារអាមេរិក សម្រាប់គម្រោងអភិវឌ្ឍន៍វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា និង គម្រោងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងខេត្តកំពង់ឆ្នាំង

រដ្ឋាភិបាលជប៉ុន បានឯកភាពផ្ដល់ថវិកាសរុបចំនួន ៦៩២,៥២២ ដុល្លារអាមេរិក ដល់អង្គការចំនួនពីរ ក្រោមគ្រោងការណ៍ជំនួយឧបត្ថម្ភឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។

កិច្ចសន្យាផ្ដល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្ដម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងអង្គភាពទទួលជំនួយទាំងពីរ សម្រាប់គម្រោងដូចតទៅ៖

**១.គម្រោងអភិវឌ្ឍន៍វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា NIPESជាគ្រឹះស្ថាន (៤ឆ្នាំសិក្សា) (ថវិកាចំនួន៣៩៦,០៣៣ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ អង្គការក្រៅរដ្ឋាភិបាល Heart of Gold

អង្គការក្រៅរដ្ឋាភិបាល Heart of Gold នឹងគាំទ្រដល់វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា ដើម្បីអភិវឌ្ឍន៍ខ្លួនអោយក្លាយទៅជាគ្រឹះស្ថាន៤ឆ្នាំសិក្សា លើកម្មវិធីសិក្សាអប់រំកាយ ដោយធ្វើការកែទម្រង់កម្មវិធីសិក្សា គ្រូបណ្ដុះបណ្ដាល និងការតម្លើងបរិក្ខារសម្រាប់ការអប់រំកាយ។

តាមរយៈគម្រោងនេះបុគ្គលិកប្រមាណ ៦៥ នាក់និងគ្រូចំនួន ២០០ នាក់ នៅក្នុងវិទ្យាស្ថាននេះនឹងអាចទទួលបាននូវបរិយាកាសកាន់តែល្អសម្រាប់ការអប់រំកាយ ហើយនិស្សិតប្រមាណ ៨០០០០០នាក់នៅក្នុងប្រទេសកម្ពុជា ត្រូវបានគេរំពឹងថានឹងទទួលបានការអប់រំកាយកាន់តែមានប្រសិទ្ធភាព។

## ២.គម្រោងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងខេត្តកំពង់ឆ្នាំង(ឆ្នាំទី២)
## (ថវិកាចំនួន២៩៦,៤៨៩ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយ: អង្គការមូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិប្រចាំប្រទេសកម្ពុជា(FIDR)

នៅក្នុងគម្រោងនេះអង្គការនេះនឹងជួយដល់កសិករនិងដៃគូពាក់ព័ន្ធដើម្បីលើកកម្ពស់ផលិតភាពនៃការដាំដុះស្រូវ ដើម្បីធ្វើពិពិធកម្មកសិកម្ម លើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ លើកកម្ពស់បណ្ដាញកសិករនិងលទ្ធភាពនៃសហករណ៍កសិកម្មនៅក្នុងស្រុករលាប្អៀរ ស្រុកទឹកផុស និងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ ប្រជាជនប្រមាណ ២៥០០០ នាក់នៅតំបន់គោលដៅត្រូវបានគេរំពឹងថានឹងទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់និងអាចថែរក្សាសុខភាពបានល្អតាមរយៈសកម្មភាពទាំងនេះ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពអង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្ថាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង២៧លានដុល្លារអាមេរិក ដល់គម្រោងចំនួន១១៣ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីន។ គម្រោងពីរនេះ គឺជាគម្រោងទី៥ និង ទី៦ ដែលបានផ្តល់ជំនួយតាមរយៈគ្រោងការណ៍នៃជំនួយនៅប្រទេសកម្ពុជា សម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៨របស់ជប៉ុន (មេសា ២០១៨ ដល់ មិនា២០១៩)៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីម៉ែល៖ eco.jpn@.pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*